# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

ភ្នំពេញ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០១៦

# សព្វថ្ងៃ កម្ពុជា ជាប្រទេសគោលដៅដ៏មានប្រជាប្រិយទីប្រាំ សម្រាប់និស្សិតញ្ញូវកូឡុមប៊ូ ណ្ណេន

នាឆ្នាំ២០១៧នេះ ប្រទេសកម្ពុជានឹងស្វាគមន៍និស្សិតកម្រិតឧត្តមសិក្សាអូស្ត្រាលីចំនួន៤៤០ នាក់ ដែលជាផ្នែកមួយនៃកម្មវិធីអប់រំញ្ញូវកូឡុមប៊ូ ណ្ណេនរបស់រដ្ឋាភិបាលអូស្ត្រាលី (NCP)។

កម្មវិធីNCP ជាគំនិតផ្តួចផ្តើមថ្មីរបស់រដ្ឋាភិបាលអូស្ត្រាលី។ វាមានគោលបំណងលើកកម្ពស់ចំណេះដឹងអំពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក តាមរយៈការគាំទ្រដល់និស្សិតអូស្ត្រាលីកម្រិតឧត្តមសិក្សាឲ្យមកបំពេញការសិក្សា និងកម្មសិក្សានៅក្នុងតំបន់នេះ។

លោកជំទាវរដ្ឋមន្ត្រីការបរទេស ប៊ីហ្សប (Bishop) បានមានប្រសាសន៍ថា «កម្មវិធីNCP បានធ្វើឲ្យមានបម្រែបម្រួលជាវិជ្ជមាន ដោយផ្តល់នូវឱកាសថ្មីដែលធ្វើឲ្យមានការរីកចម្រើននៅក្នុងជីវិតសម្រាប់អនាគតអ្នកដឹកនាំប្រទេសអូស្ត្រាលី។»

លោកជំទាវរដ្ឋមន្ត្រីការបរទេស ប៊ីហ្សប បានបន្តថា «មានអ្នកចូលរួមកម្មវិធីនេះជាច្រើនបានបញ្ជាក់ថាកម្មវិធីNCP នេះបានផ្តល់នូវការគិតគូរទូលាយជាងមុនអំពីតំបន់នេះ នៅក្នុងសេចក្តីប្រាថ្នាផ្នែកការសិក្សានិងអាជីពរបស់ពួកគេ។»

កម្ពុជាជាប្រទេសគោលដៅដ៏មានប្រជាប្រិយលំដាប់ទីប្រាំសម្រាប់និស្សិតNCP ។

នាឆ្នាំ២០១៧ នឹងមាននិស្សិតមកពីសកលវិទ្យាល័យអូស្ត្រាលីចំនួន២៤ មកបម្រើការងារក្នុងអង្គការកម្ពុជាមួយចំនួន ដើម្បីចែករំលែកនូវចំណេះដឹងនិងជំនាញរបស់ពួកគេ នៅក្នុងវិស័យជាច្រើន រួមមាន នីតិសាស្ត្រ ការថែទាំជម្ងឺ កាសែត និងវិទ្យាសាស្ត្របសុពេទ្យ។

លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា អេនជេលឡា ខកខឺរ៉ុន (Angela Corcoran) បានមានប្រសាសន៍ថា «និស្សិតក្រោមកម្មវិធីNCP នឹងវិលទៅប្រទេសអូស្ត្រាលីវិញជាមួយគំនិតនិងការយល់ដឹងថ្មីៗអំពីប្រទេសកម្ពុជា ព្រមទាំងមិត្តភាពថ្មីដែលនឹងរក្សាជាយូរអង្វែងតទៅមុខ។»

«ចំណងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន គឺជាគ្រឹះដ៏សំខាន់នៃទំនាក់ទំនងទ្វេភាគីដ៏រឹងមាំរបស់យើង។» បើតាមប្រសាសន៍របស់លោកជំទាវឯកអគ្គរាជទូត។

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

និស្សិតNCP នឹងចូលរួមក្នុងគម្រោងផ្សេងៗគ្នាជាច្រើន។ ឧទាហរណ៍ និស្សិតអូស្ត្រាលីផ្នែកគិលានុបដ្ឋាយិកានឹងរៀនអំពីប្រព័ន្ធតម្ហែទាំសុខភាពពិសេស ដូចជា ប្រព័ន្ធតម្ហែទាំសុខភាពដែលមានស្រាប់ក្នុងភូមិបណ្តែតទឹក។ និស្សិតបសុពេទ្យនឹងសហការជាមួយដៃគូកម្ពុជាក្នុងការអង្កេតអំពីឧបសគ្គផ្នែកសុខភាពសត្វរបស់កសិករខ្នាតតូច។

លោកជំទាវឯកអគ្គរាជទូត មានប្រសាសន៍បន្ថែមទៀតថា «ក្រៅពីការរួមចំណែកក្នុងការសិក្សារបស់ពួកគេ គម្រោងទាំងនេះនឹងជាឱកាសមួយសម្រាប់និស្សិតអូស្ត្រាលីដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រនិងវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជាផងដែរ។»

សំរាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វេបសាយ www.dfat.gov.au/new-colombo-plan
ឬក៏ចូលទៅ @NewColomboPlan ក្នុង Twitter

ចំពោះសំណួរពីអ្នកសារពត័មាន សូមទាក់ទង **ឡូរិន ឆូអ៊ី** ស្ថានទូតអូស្ត្រាលីភ្នំពេញ
តាមរយ: australian.embassy.cambodia@dfat.gov.au ឬ លេខទូរស័ព្ទ ០២៣ ២១៣ ៤៧០